ត្រូវបានកែសម្រួលនិងកំណត់ភារកិច្ចជូន ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ ដោះស្រាយការងារប្រចាំថ្ងៃ ជំនួសនាយករដ្ឋមន្ត្រី សម្របសម្រួលកិច្ចការសម្រាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដានសម្របសម្រួលដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យនិងសម្រេចលើការងាររបស់ "ច្រកចេញ-ចូលតែមួយ" នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលែងតែការងារដែលមានវេទយិតភាពខ្ពស់ ដែលតម្រូវឱ្យសុំការណែនាំ ឬការសម្រេចពីនាយករដ្ឋមន្ត្រី និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការពិនិត្យនិងសម្រេចលើសំណើសុំកូន និងការសុំលាសញ្ជាតិ ដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ព្រមទាំងជួយនាយករដ្ឋមន្ត្រី លើការងារដឹកនាំផ្ទាល់ក្រុមប្រឹក្សាអ្នកច្បាប់ និងការងាររៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធី ដូចមានចែងក្នុងមាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ និងជួយនាយករដ្ឋមន្ត្រីលើការងារបង្ការ ទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...១៥៥.......សហវ....

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់បុរេប្រទានសម្រាប់ឆ្នាំ២០១៧ របស់នាយកដ្ឋានសុខភាពសិក្សា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញ-វត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា ៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង អប់រំ យុវជន និកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្រ ហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកា គណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ ១ ៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" , ជំពូក៦១ "សេវាកម្ម" នៅនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មីនៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។
តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២ ៖**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានសុខភាពសិក្សា ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន** បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានសុខភាពសិក្សា

## តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន
## ថវិកាកម្មវិធីឆ្នាំ២០១៧ របស់អង្គភាពថវិកានាយកដ្ឋានសុខភាពសិក្សា

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | កាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ដុំបង្វិល រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ដុំ | ៦=៣/២ |
| | | | **សរុបរួម ៖** | **635,100,000** | **605,100,000** | **491,304,800** | **113,795,200** | **122,826,200** | **81.2%** |
| 60 | | | ការទិញ | 157,000,000 | 132,000,000 | 33,704,800 | 98,295,200 | 8,426,200 | 25.5% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 59,000,000 | 59,000,000 | 9,000,000 | 50,000,000 | 2,250,000 | 15.3% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 54,000,000 | 54,000,000 | 4,000,000 | 50,000,000 | 1,000,000 | 7.4% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 29,700,000 | 29,700,000 | 4,863,500 | 24,836,500 | 1,215,875 | 16.4% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 29,700,000 | 29,700,000 | 4,863,500 | 24,836,500 | 1,215,875 | 16.4% |
| | 6003 | | ស្បៀងអាហារ និងផលិតផលកសិកម្ម | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | | 60031 | ស្បៀង | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 56,300,000 | 31,300,000 | 7,841,300 | 23,458,700 | 1,960,325 | 25.1% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 27,300,000 | 27,300,000 | 3,841,300 | 23,458,700 | 960,325 | 14.1% |
| | | 60052 | សង្ហារឹម | 25,000,000 | | | | | #DIV/0! |
| | | 60053 | សម្ភារៈប្រើប្រាស់ | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | 6007 | | សម្ភារៈបរិក្ខារថែទាំសុខភាព | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 60072 | សម្ភារៈបរិក្ខារពេទ្យ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| 61 | | | សេវាកម្ម | 478,100,000 | 473,100,000 | 457,600,000 | 15,500,000 | 114,400,000 | 96.7% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុង និងក្រៅប្រទេស | 31,600,000 | 31,600,000 | 25,280,000 | 6,320,000 | 6,320,000 | 80.0% |
| | 6105 | | ការថែទាំនិងជួសជុល | 38,000,000 | 38,000,000 | 38,000,000 | - | 9,500,000 | 100.0% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 5,000,000 | 5,000,000 | 5,000,000 | - | 1,250,000 | 100.0% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 12,500,000 | 12,500,000 | 10,220,000 | 2,280,000 | 2,555,000 | 81.8% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 7,600,000 | 7,600,000 | 5,320,000 | 2,280,000 | 1,330,000 | 70.0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 4,900,000 | 4,900,000 | 4,900,000 | - | 1,225,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 377,000,000 | 377,000,000 | 370,100,000 | 6,900,000 | 92,525,000 | 98.2% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 50,700,000 | 50,700,000 | 50,700,000 | - | 12,675,000 | 100.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 43,200,000 | 43,200,000 | 42,410,000 | 790,000 | 10,602,500 | 98.2% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 283,100,000 | 283,100,000 | 276,990,000 | 6,110,000 | 69,247,500 | 97.8% |

| ជំពូក | គណនី | អនុគណនី | ការយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន វដ្ដទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជុំបង្វិល វដ្តទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 14,000,000 | 14,000,000 | 14,000,000 | - | 3,500,000 | 100.0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 14,000,000 | 14,000,000 | 14,000,000 | - | 3,500,000 | 100.0% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 5,000,000 | - | - | - | - | #DIV/0! |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 5,000,000 | - | - | - | - | #DIV/0! |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បណ្ឌិត ចេង ម៉ិនឥន្ទ្រាវុធ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ២០១៧
ជ.អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមគ្រូតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា

គិន_កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៧
ប្រធានអនុគ្គាពថវិកា
ពាយអគ្គានសុខភាពសិក្សា

វេជ្ជ.ឆាយគឹម សុផ្លាវី

ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧
វដ្តទេយ្យករបុរេប្រទាន

លី_រតនៈ

បានឃើញ និងឯកភាព
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៧
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០១ សហវ.ហក ១៤៥

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់ពិសេសប្រចាំឆ្នាំ២០១៧
## របស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឆ្នាំង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧នៃអនុក្រឹត្យ លេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

**សម្រេច**

**ប្រការ ១ -**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម", ជំពូក ៦៤ "បន្ទុកបុគ្គលិក", ជំពូក ៦២ "អត្ថប្រយោជន៍សង្គម" នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលនៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២ -**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ -**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ -**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

(ទំព័រទី២)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន
## ថវិកាកម្មវិធីឆ្នាំ២០១៧ របស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

ឯកតា៖ គិតជារៀល

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ដង បន្ទុល រដ្ឋទេយ្យបុរេ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ដង | ៦=៣/២ |
| | | | សរុប | 1,994,000,000.00 | 1,618,000,000.00 | 1,004,900,000.00 | 613,100,000.00 | 251,225,000.00 | 62% |
| 60 | | | ការទិញ | 1,025,000,000.00 | 1,025,000,000.00 | 509,900,000.00 | 515,100,000.00 | 127,475,000.00 | 50% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 98,400,000.00 | 98,400,000.00 | 23,400,000.00 | 75,000,000.00 | 5,850,000.00 | 24% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 5,400,000.00 | 5,400,000.00 | 5,400,000.00 | - | 1,350,000.00 | 100% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍បច្ចេកទេស | 1,000,000.00 | 1,000,000.00 | 1,000,000.00 | - | 250,000.00 | 100% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 90,000,000.00 | 90,000,000.00 | 15,000,000.00 | 75,000,000.00 | 3,750,000.00 | 17% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 84,000,000.00 | 84,000,000.00 | 84,000,000.00 | - | 21,000,000.00 | 100% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 60,000,000.00 | 60,000,000.00 | 60,000,000.00 | - | 15,000,000.00 | 100% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 24,000,000.00 | 24,000,000.00 | 24,000,000.00 | - | 6,000,000.00 | 100% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 132,600,000.00 | 132,600,000.00 | 132,600,000.00 | - | 33,150,000.00 | 100% |
| | | 60031 | ស្បៀង | 8,000,000.00 | 8,000,000.00 | 8,000,000.00 | - | 2,000,000.00 | 100% |
| | | 60032 | ចំណីសត្វ | 45,000,000.00 | 45,000,000.00 | 45,000,000.00 | - | 11,250,000.00 | 100% |
| | | 60033 | ពូជនិងកូនរុក្ខជាតិ | 14,000,000.00 | 14,000,000.00 | 14,000,000.00 | - | 3,500,000.00 | 100% |
| | | 60034 | ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី | 28,000,000.00 | 28,000,000.00 | 28,000,000.00 | - | 7,000,000.00 | 100% |
| | | 60035 | ពូជសត្វ ឱសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ | 35,600,000.00 | 36,600,000.00 | 35,600,000.00 | - | 8,900,000.00 | 100% |
| | | 60038 | ស្បៀងអាហារនិងផលិតផលកសិកម្មផ្សេងៗ | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 710,000,000.00 | 710,000,000.00 | 269,900,000.00 | 440,100,000.00 | 67,475,000.00 | 38% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 450,000,000.00 | 450,000,000.00 | 79,900,000.00 | 370,100,000.00 | 19,975,000.00 | 18% |
| | | 60052 | សង្ហារឹម | 40,000,000.00 | 40,000,000.00 | 40,000,000.00 | - | 10,000,000.00 | 100% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 220,000,000.00 | 220,000,000.00 | 150,000,000.00 | 70,000,000.00 | 37,500,000.00 | 68% |
| 61 | | | សេវាកម្ម | 426,000,000.00 | 426,000,000.00 | 426,000,000.00 | - | 106,500,000.00 | 100% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 12,000,000.00 | 12,000,000.00 | 12,000,000.00 | - | 3,000,000.00 | 100% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | 30,000,000.00 | 30,000,000.00 | 30,000,000.00 | - | 7,500,000.00 | 100% |
| | 6105 | | ការថែទាំនិងជួសជុល | 81,000,000.00 | 81,000,000.00 | 81,000,000.00 | - | 20,250,000.00 | 100% |
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ | 18,000,000.00 | 18,000,000.00 | 18,000,000.00 | - | 4,500,000.00 | 100% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 18,500,000.00 | 18,500,000.00 | 18,500,000.00 | - | 4,625,000.00 | 100% |
| | | 61053 | ការថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 16,000,000.00 | 16,000,000.00 | 16,000,000.00 | - | 4,000,000.00 | 100% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 8,000,000.00 | 8,000,000.00 | 8,000,000.00 | - | 2,000,000.00 | 100% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 18,500,000.00 | 18,500,000.00 | 18,500,000.00 | - | 4,625,000.00 | 100% |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលស្នើសុំ | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជុំ បង្វិល រជ្ជទេយ្យបុរេ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 6,000,000.00 | 6,000,000.00 | 6,000,000.00 | - | 1,500,000.00 | 100% |
| | | 61081 | សម្ភារៈនិងទំនិញ | 4,000,000.00 | 4,000,000.00 | 4,000,000.00 | - | 1,000,000.00 | 100% |
| | | 61088 | សោហ៊ុយដឹកជញ្ជូនផ្សេងៗ | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 43,000,000.00 | 43,000,000.00 | 43,000,000.00 | - | 10,750,000.00 | 100% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 1,000,000.00 | 1,000,000.00 | 1,000,000.00 | - | 250,000.00 | 100% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 8,000,000.00 | 8,000,000.00 | 8,000,000.00 | - | 2,000,000.00 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 20,000,000.00 | 20,000,000.00 | 20,000,000.00 | - | 5,000,000.00 | 100% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 1,000,000.00 | 1,000,000.00 | 1,000,000.00 | - | 250,000.00 | 100% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស | 8,000,000.00 | 8,000,000.00 | 8,000,000.00 | - | 2,000,000.00 | 100% |
| | | 61106 | ចំណាយសម្រាប់ការតាំងពិព័រណ៍ នៅក្នុងនិងក្រៅប្រទេស | 4,000,000.00 | 4,000,000.00 | 4,000,000.00 | - | 1,000,000.00 | 100% |
| | | 61108 | សោហ៊ុយទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ | 1,000,000.00 | 1,000,000.00 | 1,000,000.00 | - | 250,000.00 | 100% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាននិងឯកសារ | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 1,000,000.00 | 1,000,000.00 | 1,000,000.00 | - | 250,000.00 | 100% |
| | | 61112 | ចំណាយលើការជាវទស្សនាវដ្ដី | 1,000,000.00 | 1,000,000.00 | 1,000,000.00 | - | 250,000.00 | 100% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 200,000,000.00 | 200,000,000.00 | 200,000,000.00 | - | 50,000,000.00 | 100% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 40,000,000.00 | 40,000,000.00 | 40,000,000.00 | - | 10,000,000.00 | 100% |
| | | 61122 | សោហ៊ុយបេសកកម្ម | 28,000,000.00 | 28,000,000.00 | 28,000,000.00 | - | 7,000,000.00 | 100% |
| | | 61123 | សោហ៊ុយស្នាក់នៅ និងហូបចុក | 132,000,000.00 | 132,000,000.00 | 132,000,000.00 | - | 33,000,000.00 | 100% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 40,000,000.00 | 40,000,000.00 | 40,000,000.00 | - | 10,000,000.00 | 100% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 8,000,000.00 | 8,000,000.00 | 8,000,000.00 | - | 2,000,000.00 | 100% |
| | | 61132 | សោហ៊ុយបេសកកម្ម | 24,000,000.00 | 24,000,000.00 | 24,000,000.00 | - | 6,000,000.00 | 100% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 8,000,000.00 | 8,000,000.00 | 8,000,000.00 | - | 2,000,000.00 | 100% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 12,000,000.00 | 12,000,000.00 | 12,000,000.00 | - | 3,000,000.00 | 100% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 10,000,000.00 | 10,000,000.00 | 10,000,000.00 | - | 2,500,000.00 | 100% |
| 64 | | | បន្ទុកបុគ្គលិក | 388,000,000.00 | 12,000,000.00 | 12,000,000.00 | - | 3,000,000.00 | 100% |
| | 6402 | | លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | 224,000,000.00 | - | - | - | - | #DIV/0! |
| | | 64023 | ប្រាក់បំណាច់ម៉ោងបន្ថែម | 118,000,000.00 | - | - | - | - | #DIV/0! |
| | | 64026 | ប្រាក់បំណាច់តំបន់ | 106,000,000.00 | - | - | - | - | #DIV/0! |
| | 6403 | | រង្វាន់និងប្រាក់បំណាច់ផ្សេងៗ | 162,000,000.00 | 12,000,000.00 | 12,000,000.00 | - | 3,000,000.00 | 100% |
| | | 64032 | ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង | 150,000,000.00 | - | - | - | - | #DIV/0! |
| | | 64033 | រង្វាន់ | 2,000,000.00 | 2,000,000.00 | 2,000,000.00 | - | 500,000.00 | 100% |
| | | 64038 | ប្រាក់បំណាច់ផ្សេងៗ | 10,000,000.00 | 10,000,000.00 | 10,000,000.00 | - | 2,500,000.00 | 100% |
| | 6405 | | ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ | 2,000,000.00 | - | - | - | - | #DIV/0! |
| | | 64051 | មន្ត្រីមានជំងឺ | 2,000,000.00 | - | - | - | - | #DIV/0! |
| 62 | | | អត្ថប្រយោជន៍សង្គម | 155,000,000.00 | 155,000,000.00 | 57,000,000.00 | 98,000,000.00 | 14,250,000.00 | 37% |
| | 6202 | | ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 123,000,000.00 | 123,000,000.00 | 25,000,000.00 | 98,000,000.00 | 6,250,000.00 | 20% |
| | | 62025 | អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស | 115,000,000 | 115,000,000 | 17,000,000 | 98,000,000 | 4,250,000.00 | 15% |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលស្នើសុំ | ឥណទាន វដ្តទេយ្យបុរេ ប្រទាន | ឥណទាន ទូទាត់បន្ទាន់ | ឥណទាន១ជុំ បង្វិល វដ្តទេយ្យបុរេ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | | 62026 | អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវ ក្រៅប្រទេស | 8,000,000 | 8,000,000 | 8,000,000 | - | 2,000,000.00 | 100% |
| | 6203 | | ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈ សង្គមនិងវប្បធម៌ | 32,000,000 | 32,000,000 | 32,000,000 | - | 8,000,000.00 | 100% |
| | | 62033 | ឧបត្ថម្ភដំណើរលំហែនិងសិក្សា | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000.00 | 100% |
| | | 62035 | ឧបត្ថម្ភសហគមន៍កីឡានិងវប្បធម៌ | 12,000,000 | 12,000,000 | 12,000,000 | - | 3,000,000.00 | 100% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧
ក. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ្ញ បានសុវណ្ណអាទិច្ចាសីហា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧
ជ.អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
នៃក្រសួងអប់រំ យុវជន និងកីឡា
គីន_កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧
នាយកវិទ្យាស្ថាន
បណ្ឌិត.ម៉ិច_សៀង

ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧
វដ្តទេយ្យករបុរេប្រទាន
សុខ_យ៉ឹន

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៧
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិត ហង់ ជួន ណារ៉ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-០៤៣ ប្រ.ក

## ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៨.៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ១.០១០.១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមសំណើរបស់អគ្គលេខាធិការដ្ឋាន

## ស ម្រេ ច

**ប្រការ ១.~**

បង្កើតគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះ ហៅថា "**គណៈកម្មាធិការ**" ។

**ប្រការ ២.~**

គណៈកម្មាធិការនេះ រួមមានសមាសភាពចំនួន ៩រូប ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម ជា ចាន់តូ | ទេសាភិបាល | ប្រធាន |
| ២. ឯកឧត្តម ស៊ុំ សន្និសិទ្ធ | ទេសាភិបាលរង | អនុប្រធាន |
| ៣. លោក អ៊ូ ចាន់តារា | អគ្គលេខាធិការ | សមាជិក |
| ៤. លោកជំទាវ ជា សិរី | អគ្គនាយកបច្ចេកទេស | សមាជិក |



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

| | | |
|---|---|---|
| ៥. លោក វ័ឌ្ឍ សុវណ្ណនរៈ | អគ្គនាយកត្រួតពិនិត្យ | សមាជិក |
| ៦. លោក គីមទី កោមលី | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ៧. លោក យូ វុណ្ណី | អគ្គនាយករងបច្ចេកទេស និងជាប្រធាននាយកដ្ឋានស.ស.អ | សមាជិកអចិន្ត្រៃយ៍ |
| ៨. លោក ម៉ក់ វត្ថា | ប្រធាននាយកដ្ឋានប្រតិបត្តិការ | សមាជិក និង |
| ៩. លោក លី ស៊ីដេត | ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | សមាជិក ។ |

**ប្រការ ៣.-**

គណៈកម្មាធិការនេះ អាចដំណើរការកិច្ចប្រជុំបានលុះត្រាតែមាន ទេសាភិបាល ជាប្រធាន និងមានសមាជិកយ៉ាងតិចចំនួន ៦រូប ។ សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។ ប្រធានគណៈកម្មាធិការអាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញផ្សេងទៀត ចូលរួមក្នុងការប្រជុំតាមការចាំបាច់ ។

**ប្រការ ៤.-**

ការប្រជុំរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងយ៉ាងហោចណាស់បីខែម្តង ដើម្បីវាយការណ៍ពី ស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុ ។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានគណៈកម្មាធិការអាចកោះប្រជុំគណៈកម្មាធិការនៅពេលណាក៏បាន ។

**ប្រការ ៥.-**

គណៈកម្មាធិការមានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- កំណត់និងដឹកនាំការអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ក្នុងក្របខ័ណ្ឌនៃគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល សំដៅរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជួយទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច
- ដាក់ចេញនូវវិធានការចាំបាច់ សំដៅធ្វើឱ្យស្ថានភាពសន្ទនីយភាពក្នុងទីផ្សាររូបិយវត្ថុ ស្របតាមគោលដៅនៃការរក្សាស្ថិរភាពថ្លៃ
- សម្របសម្រួលទៅតាមលទ្ធភាពជាមួយសមាសធាតុផ្សេងៗនៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ពិសេសគោលនយោបាយសារពើពន្ធ សំដៅទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
- សម្របសម្រួលទំនាក់ទំនងរវាងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ននៃការត្រួតពិនិត្យធនាគារ និង
- ផ្សព្វផ្សាយគោលនយោបាយរូបិយវត្ថុ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

**ប្រការ ៦.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការនេះ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការមានក្រុមការងារជំនួយការមកពីនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ។ សមាសភាពក្រុមការងារត្រូវតែងតាំងដោយសេចក្តីបង្គាប់ការ និងមានមុខងារ-ភារកិច្ចដូចខាងក្រោម ៖

- តាមដាន ប្រមូល និងចងក្រងព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា និន្នាការសេដ្ឋកិច្ច ស្ថិតិរូបិយវត្ថុ ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មាធិការក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ វិធានការ ឬឧបករណ៍គោលនយោបាយរូបិយវត្ថុ

- វិភាគនិងវាយតម្លៃពីបញ្ហាប្រឈម និងផលប៉ះពាល់ដែលនាំឱ្យមានសម្ពាធអតិផរណា ព្រមទាំងលើកឡើងពីជម្រើសនៃការដោះស្រាយជាគោលនយោបាយ ដើម្បីគណៈកម្មាធិការពិនិត្យនិងសម្រេចចេញជាវិធានការអនុវត្ត និង

- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មាធិការ ផ្ញើជូនទៅថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីជ្រាបជាព័ត៌មាននិងសហការអនុវត្ត ។

**ប្រការ ៧.-**

កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការ ត្រូវរៀបចំឱ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ ។

**ប្រការ ៨.-**

ប្រកាសស្តីពីការបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ លេខ ធ១៣-០១៤-០៦៩ ប្រ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុង ប្រការ២ ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៧

**ទេសាភិបាល**

**ជា.ចាន់តូ**

កន្លែងទទួល :
- ដូចប្រការ ២ និងប្រការ ៩
"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ចម្លងជូន :
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.១២ ០១៧ ១១២ ប្រ.ក

# ប្រកាស
## ស្តីពី
## ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រី-បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

*******

## ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៥១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់ត្ូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៥៦ អនក្រ.តត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមស្មារតីរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់សីលធម៌វិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ គុណភាព និងប្រសិទ្ធភាពការងាររបស់មន្ត្រី-បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាតទៅនេះហៅថា "ស.ហ.ក" ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រី-បុគ្គលិក ស.ហ.ក ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រី-បុគ្គលិកដែលបាននិងកំពុងបម្រើការងារជូន ស.ហ.ក ។

## ជំពូកទី២
## ករណីយកិច្ច និងការទទួលខុសត្រូវទូទៅ

**ប្រការ ៤.-**

មន្ត្រី-បុគ្គលិក ដែលបាននិងកំពុងបំពេញមុខងារនិងភារកិច្ចជូន ស.ហ.ក. ត្រូវមានករណីយកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

១- គោរពជីវិត រាងកាយ ចិត្ត សេចក្តីថ្លៃថ្នូររបស់មនុស្ស គោរពវិន័យការងារ បទបញ្ជាផ្ទៃក្នុង និងត្រូវប្រកាន់ខ្ជាប់នូវសីលធម៌វិជ្ជាជីវៈ

២- ស្មោះត្រង់ និងមានភាពសុចរិតឥតល្អៀងចំពោះ ស.ហ.ក

៣- មានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខងារនិងភារកិច្ចដែល ស.ហ.ក ប្រគល់ជូន និងត្រូវអនុវត្តការងារនោះឲ្យមានប្រសិទ្ធភាពជូនអង្គភាព និងសង្គមជាតិ

៤- មានកាតព្វកិច្ចគោរពគោលការណ៍រក្សាការសម្ងាត់វិជ្ជាជីវៈនៃព័ត៌មាន ក្នុងក្របខ័ណ្ឌការងាររបស់ខ្លួន ។ កាតព្វកិច្ចនេះនៅតែត្រូវបន្តអនុវត្ត ទោះបីមន្ត្រី-បុគ្គលិកនោះបានឈប់បម្រើការងារពី ស.ហ.ក ហើយក៏ដោយ ស្របតាមមាត្រា២៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៥- ខិតខំអភិវឌ្ឍខ្លួនឯង តាមរយៈការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឲ្យមាន គុណភាព និងប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី៣
## ទំនាក់ទំនងផ្ទៃក្នុង និងភាគីពាក់ព័ន្ធ

**ប្រការ ៥.-**

មន្ត្រី-បុគ្គលិកត្រូវគោរពនិងប្រតិបត្តិតាមឋានានុក្រមរដ្ឋបាល មានទំនាក់ទំនងនិងសាមគ្គីផ្ទៃក្នុងល្អ ដើម្បីកសាងវប្បធម៌ការងារគំរូ និងសេចក្តីថ្លៃថ្នូរ ។

**ប្រការ ៦.-**

មន្ត្រី-បុគ្គលិកត្រូវមានទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ ដោយប្រកាន់ខ្ជាប់នូវសីលធម៌ សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាទន់ភ្លន់ ស្លូតបូត សុភាពរាបសា និងរួសរាយរាក់ទាក់ ក្នុងពេលបំពេញមុខងារនិងភារកិច្ចជូន ស.ហ.ក ។

## ជំពូកទី ៤
## ការហាមឃាត់ចំពោះមន្ត្រី-បុគ្គលិក ស.ហ.ក

**ប្រការ ៧.-**

មន្ត្រី-បុគ្គលិកមិនត្រូវធ្វើឲ្យបាត់បង់មនសិការរបស់ខ្លួនក្នុងការបំពេញមុខងារនិងភារកិច្ច ដែលបណ្តាលឲ្យប៉ះពាល់ដល់គុណភាព ប្រសិទ្ធភាពការងារ និងកេរ្តិ៍ឈ្មោះរបស់ ស.ហ.ក និងផលប្រយោជន៍សង្គមជាតិ ។

**ប្រការ ៨.-**

មន្ត្រី-បុគ្គលិក ស.ហ.ក ៖

- មិនត្រូវបរិហាកេរ្តិ៍ ប្រមាថ ឬមើលងាយថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក ឬដៃគូពាក់ព័ន្ធ
- មិនត្រូវកេងចំណេញពី ស.ហ.ក សម្រាប់ជាផលប្រយោជន៍ផ្ទាល់ខ្លួន ក្រុមនិង/ឬ សម្រាប់ស្ថាប័ន និងអង្គភាពផ្សេង ទោះបីក្រោមរូបភាពណាក៏ដោយ
- មិនត្រូវផ្សព្វផ្សាយអំពីការវិនិច្ឆ័យរដ្ឋបាលចំពោះមន្ត្រី-បុគ្គលិកណាម្នាក់ លិខិតស្នាម រដ្ឋបាល និងព័ត៌មានផ្ទៃក្នុងរបស់ ស.ហ.ក តាមប្រព័ន្ធផ្សព្វផ្សាយនានាដោយគ្មានការអនុញ្ញាតឡើយ
- ត្រូវចៀសវាងរាល់ការទទួលយកអំណោយ លាភសក្ការៈ ឬ/និងផលប្រយោជន៍ផ្សេងៗ ដែលធ្វើឲ្យប៉ះពាល់ដល់សកម្មភាព គុណភាព និងប្រសិទ្ធភាពការងារ ព្រមទាំងកេរ្តិ៍ឈ្មោះរបស់ ស.ហ.ក
- មិនត្រូវលេងល្បែងស៊ីសង និងកេងប្រវ័ញ្ច ដែលអាចប៉ះពាល់ដល់កិត្យានុភាព និងសេចក្តីថ្លៃថ្នូររបស់ ស.ហ.ក
- មិនត្រូវប្រព្រឹត្ត ឬបំពេញការងារណាដែលផ្ទុយពី ច្បាប់ ទំនៀមទម្លាប់ វប្បធម៌ និងប្រពៃណីជាតិឡើយ
- ត្រូវចៀសវាងរាល់ការរើសអើងជាតិសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា កាយសម្បទា អាយុ ភេទ និងទស្សនៈនយោបាយផ្សេងៗ ។

**ប្រការ ៩.-**

មន្ត្រី-បុគ្គលិកមិនត្រូវបានអនុញ្ញាតឲ្យទៅបម្រើការងារក្នុងមុខតំណែង ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់សហព័ទ្ធឡើយ ។

**ប្រការ ១០.-**

មន្ត្រី-បុគ្គលិកមិនត្រូវបានអនុញ្ញាតឲ្យទៅបម្រើការងារក្នុងមុខតំណែងណាមួយរបស់បុគ្គលពាយការណ៍ ដែលខ្លួនធ្លាប់ពាក់ព័ន្ធ ឬនាំឲ្យមានទំនាស់ផលប្រយោជន៍មុនពេលលាឈប់ពីការងារ ឬចូលនិវត្តន៍ ក្នុងរយៈពេល១(មួយ)ឆ្នាំយ៉ាងតិច លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាភិបាល ស.ហ.ក ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ១១.-**

លេខាធិការដ្ឋាន ស.ហ.ក ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៧

**ទេសាភិបាល**

**និងជាប្រធានក្រុមប្រឹក្សាភិបាល**

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

ស.ហ.ក

**ជា.ចាន់តូ**

កន្លែងទទួល
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ដូចប្រការ ១១
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ..០.១១/ការ១
/២០១៧

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការរៀបចំពិធីផ្ទេរ-ប្រគល់សម្ភារៈជំនួយ**
**ពីសាធារណរដ្ឋកូរ៉េ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ខែកក្កដា ឆ្នាំ២០០១ស្តីពីការកែសម្រួលភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- ស្មារតីនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងការពារជាតិ នៃសាធារណរដ្ឋកូរ៉េ និងក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ លើលិខិតលេខ ១៣៨/២០១៧ ស.ណ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងការពារជាតិ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីផ្ទេរ-ប្រគល់សម្ភារៈយោធាជំនួយពីសាធារណរដ្ឋកូរ៉េ មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-នាយឧត្តមសេនីយ៍ | **ថៅ ភិរុណ** | អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | ប្រធាន |
| ២-ឧត្តមសេនីយ៍ឯក | **ខៀវ ឆេន** | អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស | អនុប្រធាន |
| ៣-ឧត្តមសេនីយ៍ឯក | **ប៉ាង ផារ៉ូ** | អគ្គលេខាធិការរង និងជានាយក នាយកដ្ឋានកិច្ចការរដ្ឋបាល | អនុប្រធាន |
| ៤-ឧត្តមសេនីយ៍ឯក | **កើត ណារុធ** | អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក | **លី កុសល** | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ និងជានាយក នាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ៦-ឧត្តមសេនីយ៍ឯក | **វង្ស ពិសេន** | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៧-ឧត្តមសេនីយ៍ឯក | **ថៅ ភីរិទ្ធ** | អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស និងជានាយក នាយកដ្ឋានយន្តយុទ្ធ | សមាជិក |
| ៨-ឧត្តមសេនីយ៍ឯក | **សូ សូច័ន្ទ** | នាយក វិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន | សមាជិក |
| ៩-ឧត្តមសេនីយ៍ទោ | **ថៅ ពលៈ** | នាយក នាយកដ្ឋានបច្ចេកទេសកងទ័ពជើងអាកាស អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១០-ឧត្តមសេនីយ៍ទោ | **គង់ វ៉ាន់នរិទ្ធ** | នាយក នាយកដ្ឋានយានយន្ត អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១១-ឧត្តមសេនីយ៍ទោ | **អ៊ុំ វន្នី** | នាយករង ទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋាន | សមាជិក |
| ១២-ឧត្តមសេនីយ៍ទោ | **នួន សុខូ** | នាយករង នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ | សមាជិក |
| ១៣-ឧត្តមសេនីយ៍ទោ | **សូ សំអន** | នាយករង នាយកដ្ឋានព័ត៌មាននិងជានាយផែនការ អគ្គនាយកដ្ឋានយោធសេវា | សមាជិក |
| ១៤-ឧត្តមសេនីយ៍ទោ | **ប៊ុត រម្យ** | នាយករង នាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ | សមាជិក |
| ១៥-ឧត្តមសេនីយ៍ទោ | **វេង សុខហេង** | នាយករង នាយកដ្ឋានព័ត៌មាន អគ្គនាយកដ្ឋានយោធសេវា | សមាជិក |
| ១៦-ឧត្តមសេនីយ៍ទោ | **ឡាច ឆឹន** | នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស | សមាជិក |
| ១៧-ឧត្តមសេនីយ៍ទោ | **ហៅ សំអឿន** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១៨-ឧត្តមសេនីយ៍ទោ | **ខែក យូលីផល** | នាយករង នាយកដ្ឋានបច្ចេកទេសកងទ័ពជើងអាកាស អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១៩-ឧត្តមសេនីយ៍ទោ | **ឌុយ សាម៉េត** | នាយករង វិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុនសែន | សមាជិក |

| | | | |
|---|---|---|---|
| ២០-ឧត្តមសេនីយ៍ទោ | **សូ សុធា** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ២១-ឧត្តមសេនីយ៍ទោ | **យ៉ិល សុធី** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ២២-ឧត្តមសេនីយ៍ទោ | **អ៊ឹម សារ៉ា** | នាយករង នាយកដ្ឋានបំពាក់សម្ភារៈសឹក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |

**ប្រការ២.-**

គណៈកម្មការមានភារកិច្ចដូចតទៅ ៖

-រៀបចំផែនកងកិត្តិយស-ត្រែទ័ព

-អញ្ជើញភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ចូលរួមពិធី

-ចុះពិនិត្យទីតាំង រៀបចំវេទិកាកិត្តិយស និងរៀបចំការដាក់តាំងបង្ហាញផ្សេងៗ

-រៀបចំមធ្យោបាយដឹកជញ្ជូន និងសម្របសម្រួលការងារពិធីការផ្សេងៗ

-រៀបចំសុន្ទរកថាជូនឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

-រៀបចំសុន្ទរកថាស្វាគមន៍របស់ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

-រៀបចំកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ក្នុងពេលដំណើរការពិធី

-លើកគម្រោងថវិកាចំណាយ និងប្រេងឥន្ធនៈ សំរាប់ដំណើរការពិធី

-អនុវត្តភារកិច្ចផ្សេងទៀតតាមប្រធានគណៈកម្មការប្រគល់ជូន ។

**ប្រការ៣.-**

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៤.-**

អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយកនាយកដ្ឋាន ប្រធានស្ថាប័ន មេបញ្ជាការកងឯកភាពដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍.ទៀ~បាញ់**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការ រាជរដ្ឋាភិបាល

-ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រីក.ព.ជ

-ដូចប្រការ ៤

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី